# ១ - ប្រពៃណីអ្នកស្រុកចេនលា

## សេចក្ដីផ្ដើម

រឿងរ៉ាវទាំងនេះ លោកជីវ តាក់គង់(១) បាននិពន្ធឡើងក្នុងសម័យសន្តិវង្ស ងន់(២) គឺនៅស្រុក វេងតា(៣)ហើយក្រោយមកលោកហ្វូវគង់ បានកែសំរួលក្នុងរវាង រាជសន្តិវង្ស ម៉េង(៤)ក្នុងស្រុកសេងអាន(៥)

១ = នេះតាមសំលេងចិនទាជីវ បើអានតាមសំលែងចិនប៉េកាំង : ចូវតាក្វាន់ តែយើងធ្លាប់មកថា ជីវតាក្វាន់ៗ។
២ = សន្តិវង្សងន់នេះ មានស្ដេចច្រើនអង្គ តែនេះក្នុង គ.ស ១២៩៥ គឺត្រូវលើស្ដេចឈ្មោះ ងន់ សេងចុង នាមសំរាប់រាជវង្ស ងន់ចេង។ ៣ = ស្រុកវេងតា នៅក្នុងខេត្តជាក់កាង (ចិនខាងត្បូង)។ ៤ = សន្តិវង្សម៉េង ចូលមកក្នុងសតវត្សទី ១៣ -១៤ នៃគ.ស។ ៥ = នៅក្នុងខេត្តហោណាំ (ហូណាន់)។

## សេចក្ដីអធិប្បាយទាំងស្រុងមានដូចតទៅ៖

ចេនឡា រឺ ចាមឡា អ្នកប្រទេសហៅខ្លួនអែងថា «កាន់ផៃចី» តាមកំនត់ខ្លះរបស់ពួកបស្ចិមប្រទេស បានហៅថាកាំពូចឺ ដែលមានសំលេងស្រដៀងនឹង «កាំពូចេ» ដែរ។
ខ្ញុំចាប់ធ្វើដំនើរចេញពីស្រុក «អ៊ូជីវ» ទៅដល់សមុទ្រ «ការជីវ» ក៏បានទៅដល់ទីក្រុងចាម្ប បន្តដំនើរបន្ដោយខ្យល់ចេញពីក្រុងចាម្ប ទៅអស់រយៈពេលកន្លះខែទៀត ក៏បានទៅដល់ស្រុក ចេញផូវ (ជម្ពូ?) ដែលជាព្រំដែននៃប្រទេសនេះ។ លុះចេញពីចេងផូវទៅទៀត ឆ្លងសមុទ្រ យុនលុន ក៏ទៅដល់មាត់ពាម គឺបែកចេញពីមាត់សមុទ្រទៅជាដៃទន្លេច្រើនច្រកណាស់។ក្នុងបន្ដាច្រកទាំងនោះ មានតែច្រកទី៤ទេ ទើបអាចចូលទៅបាន ក្រៅពីនេះគេដឹងថា មានទឹករាក់ណាស់ នាវាធំៗមិនអាចធ្វើដំនើរបានឡើយ ត្រង់ពាមមានច្រកនោះ ឃើញមានព្រៃទ្រុប ហើយក្រៅពីនេះមានវាលខ្សាច់ពណ៌លឿង និងមានដើមបបូសនិងអំពៅព្រៃ ដុះបែកផ្កាសសំព្រូស ម្លោះហើយ អ្នកដំនើរពិបាកចំនាំច្រកចូលទៅណាស់។

ចូលផុតពីមាត់ពាម ធ្វើដំនើរប្រមាណកន្លះខែទៀត ទើបបានទៅដល់ស្រុកមួយឈ្មោះ ឆេនាំ (ឆ្នាំង?) ដែលជាខេត្តមួយនៃប្រទេសនេះ។ លុះធ្វើដំនើរពី ឆេនាំ បន្តោយតាមទឹកហូរទៅជើង អស់ពេល ១០ថ្ងៃទៀត កាត់ភូមិ ពូលូវឈឹង (ប្រែថាភូមិកន្ដាលផ្លូវ) ហ៊ុតឈឹង (ភូមិព្រះពុទ្ធ)(១) ឆ្លងកាត់សមុទ្រទឹកសាប(២) ទៅទៀត ទើបបានដល់ទីក្រុង កាងពាងឈូ (កំពែងជូវ?)។ ក្នុងនេះ មានទំហំ ៥០ លី (១លីប្រវែង ១.៨០០ហត្ថ) បើតាមសៀភៅពួកបស្ចិមប្រទេសសរសេរថា ប្រទេសនេះ មានទំហំដី៧.០០០លី និងមានព្រំប្រទល់ ខាងជើងទល់នឹងក្រុងចំប៉ា គឺត្រូវធ្វើដំនើរ អស់ពេលកន្លះខែ ខាងនិរតីនៅឃ្លាតពីស្រុកសៀមចំងាយផ្លូវកន្លះខែដែរ នៅខាងត្បូងឃ្លាតពីទីក្រុង «ហ្វូងអ៊ូ» ចំងាយផ្លូវ១០ថ្ងៃ អែខាងកើតប្រទេសនេះគឺមហាសមុទ្រ ហើយដែលប្រទេសមួយធ្លាប់ទាក់ទង ខាងសេដ្ឋកិច្ចជាមួយ ស្រុកយើងតាំងពីដើមរៀងមកផង។

១ = លោក ប៉េលីយោត Pelliot សង្ស័យថា ពោធិសាត់ តែពិតគឺ ភូមិព្រៃភព ព្រោះជាពាក្យសំគាល់នាមព្រះពុទ្ធដែរ។ ២ = ពាក្យ ទលេបាលី ប្រែថាសមុទ្ទ សព្វថ្ងៃក្លាយជា ទន្លេសាបវិញ។

នៅគ្រាដែលប្រទេសចិន (ក្នុងរាជ្យសន្តិវង្សម៉ុងហ្គោល) បានត្រួត្រាលើមហាសមុទ្រក្នុងទ្វីបលោកហើយ លោក

ថមពល (មេទ័ពធំ) ឈ្មោះ ចុន តូវ ដែលនៅឈរប្រចាំការត្រួតត្រាទីក្រុងចាមបានចាត់ មន្ត្រីពីរនាក់គឺ លោក ហ៊្វ ប៉េក ហូវ អ្នកមានប៉ានមាស១ និងលោក ឆាយ ហូវ អោយទៅកាន់ប្រទេសចេនលា តែត្រូវប្រទេសនេះចាប់ឃុំទុកមិនអោយមកវិញ។ លុះមកដល់រជ្ជកាលស្តេច ងន់ ចេង (គ.ស.១២៩២) ខែទី៦ ព្រះរាជាអង្គនេះ ទ្រង់ចាត់បេសកម្មទូតមួយមកប្រទេសចេនលា ហើយពេលនោះ ខ្លួនខ្ញុំក៏ត្រូវចាត់មកជាមួយដែរ។ គឺនៅក្នុងខែទី ២នៃឆ្នាំបន្ទាប់មក យើងបានចាកចេញពីស្រុក ម៉េងជីវ នោះមកទៀត។ លុះថ្ងៃ១៥ ខែទី៣ ទើបដល់ទីក្រុងចាម នៅកន្តាលផ្លូវជួបនឹងខ្យល់បក់បញ្ច្រាសពីមុខមកវិញ ដែលជាហេតុនាំអោយមានការ រអាក់រអួលក្នុងដំនើរ។ ដល់មកខែ ៧ដែលជាសរទរដូវ ទើបបានមកដល់ប្រទេសនេះ ព្រមចំនុចចុះចូលទៅ(១)។
១ = ត្រង់នេះ តាមសេចក្តីប្រែលោក ប៉េលីយោត មិនលឺថា ព្រមចំនុចចូលទេ តែនេះប្រែតាមប្រយោគចិន អក្សរដូច្នេះន័យនេះបានត្រឹមតែថាគេព្រមរាក់ទាក់ទទួលបេសកជនប៉ុណ្ណោះ។

លុះដល់មករជ្ជកាលស្តេច តាយ តេក (គ.ស. ១២៩៧) ខែទី៦ ខ្ញុំជិះនាវាត្រលប់មកវិញ ហើយដល់ថ្ងៃ ១២ ខែ ៨ ទើបនាវាចូលចត ដល់កំពង់ផែស្រុកស៊ីម៉េង។
ចំពោះរឿងប្រពៃណី និង កិច្ចការនៃប្រទេសចេនលានេះ ខ្ញុំមិនបានដឹងល្អិតល្អន់អស់សេចក្តីសព្វគ្រប់មែន តែខ្ញុំបានដឹងដោយត្រួសៗអាចនឹងជំរាបបានដែរ។

## ១. បរិវេណនៃក្រុង

បរិវេណនៃក្រុងនេះ មានទំហំ ២០លី មានទ្វារ ៥។ ទ្វារទាំងនោះសុទ្ធតែសាងកំរាស់ជាពីរជាន់ក្នុងក្រៅ គឺនៅទិសខាងកើតមានទ្វារពីរ។ ក្រៅពីនេះ ក្នុងមួយទិស មានទ្វារតែមួយទេ។ នៅក្រៅកំពែងក្រុង សុទ្ធតែមានប្រលាយទឹកធំៗ ពីក្រៅប្រលាយនោះមានផ្លូវដើរទៅកាន់ស្ពានធំៗ ហើយនៅសងខាងស្ពាននិមួយៗមានទេវរូបថ្ម ៥៤ ដូចជាមេទ័ពថ្មដ៏ធំៗដូច្នេះដែរ។ រូបទាំងនោះដូចៗគ្នានៅតាមច្រកទាំងប្រាំ។ បង្កាន់ដៃស្ពានទាំងនេះគេធ្វើអំពីថ្ម ហើយមានឆ្លាក់រូប ពស់ដ៏ធំ(១) ដែលមានក្បាល៩ អែរូបថ្មទាំង ៥៤នោះ សុទ្ធតែយកដៃចាប់ទាញពស់នេះអែងហាក់ដូចជាមិនចង់អោយស្ទុះទៅរួច។ នៅខាង លើខ្លោងទ្វារ មានពុទ្ធរូបថ្មប្រាំអង្គបែរភ័ក្ត្រទៅទិសខាងលិច ហើយមួយអង្គដែលស្ថិតនៅចំកន្តាលគេមានទឹកមាសល្អស្រស់ផង។ នៅសងខាងទ្វារ មានឆ្លាក់រូបដំរីថ្មទៀត។
១ = ពស់នេះ បើតាមខ្មែរគឺជានាគ។ ជីវតាក្វាន់ធ្លាប់ស្គាល់នាគចិន មានរូបផ្សេងបានជាហៅនាគខ្មែរថាពស់

កំពែងទីក្រុង គេធ្វើពីថ្មទាំងអស់ មានកំពស់ ២០ ហត្ថតំរៀបថ្មយ៉ាងជិត ហើយមាំណាស់។ នៅពីលើគ្មានស្មៅដុះឡើយ តែនៅ ចន្លោះមួយដុំៗមានដាំដើមជ្រៃ។ អែផ្ទៃក្នុងនៃកំពែងដែលមានចន្លោះពីគ្នាដល់ទៅ ១០០ហត្ថនោះស្ថិតនៅជាដីជំរាល បីដូចជាជំរាលនៃភ្នំ រលីងស្អាតណាស់។ លើកំពែងដែលមានផ្ទៃជាជំរាលនោះ មានទ្វារធំៗដែលបិទជិតនៅពេលយប់ ហើយបើកចំហរនៅពេលថ្ងៃតាំងពីព្រលឹម និងមានអ្នកយាមប្រចាំការជានិច្ច។ សត្វឆ្កែគេមិនអោយចូលក្នុងទ្វារនេះទេ។ ជនណាដែលធ្លាប់មានទោសត្រូវគេកាត់ម្រាមជើង ក៏មិនអោយចូលដែរ។ កំពែងព័ទ្ធជុំវិញនោះមានជ្រុងជ្រោយល្អណាស់ ហើយនៅជ្រុងនិមួយៗសឹងមានប្រាង្គថ្មមួយខ្ពស់នៅប្រចាំគ្រប់ជ្រុង។

នៅកន្តាលទីក្រុងនេះ មានប្រសាទមាសមួយ(ក) និងនៅជិតខាងនេះមានប្រាង្គប្រាសាទជាង២០ទៀត ព្រមទាំងមានបន្ទប់ថ្មចំនួនច្រើនបន្ទប់ផង ។ នៅប៉ែងខាងកើតមានស្ពានមាសមួយមានរូបតោមាស២ ស្ថិតនៅអមខាងឆ្វេង និងខាងស្តាំស្ពានមាស។ មានព្រះពុទ្ធរូបមាស ៨អង្គ តំកល់នៅតំរៀបគ្នាចំពីក្រោមប្រាង្គសិលា។ នៅខាងជើងប្រាសាទមាសចំងាយប្រមាណជាងមួយលី មានប្រាសាទស្ពាន់មួយទៀតដែលមានកំពស់ខ្ពស់ជាងប្រាសាទមាស គួរអោយគយគន់ណាស់។ ចំពីក្រោមប្រាសាទស្ពាន់នោះ ឃើញមានបន្ទប់ថ្មប្រហែលជាដប់ដែរ។ ចេញពី

នេះទៅខាងជើងថែមមួយលីទៀត គឺជាព្រះរាជដំនាក់ដែលស្តេចគង់នៅ។ នៅក្នុងល្វែងដែលជាព្រះដំនាក់នោះមានប្រាង្គមាសមួយទៀត។ ទំនងជាដោយហេតុនេះហើយ ដែលពួកឈ្មួញបរទេសតែងដំនាលថា ប្រទេសចេនលាថ្កុំថ្កើងរុងរឿងណាស់។

ក = លោកប៉េលីយោត យល់ថាប្រាសាទនេះ គឺប្រាសាទបាយ័ន។

ចេញពីកំពែងតាមទ្វារខាងត្បូងទៅ ចំងាយប្រមាណជាជាងកន្លះលី តាមពាក្យចចាមអារាមគេនិយាយថាចេតិយលូប៉ិន(១) សង់តែមួយយប់។ ផ្នូរសព រឺ ចេតីយ លូប៉ិន ស្ថិតនៅក្រៅកំពែងខាងត្បូងជាងកន្លះលី ហើយមានបរិវេណព័ទ្ធជុំវិញប្រមាណជាងដប់លី និងមានបន្ទប់ថ្មច្រើនរយទៀតផង។ នៅស្រះខាងកើតកំពែងនគរប្រមាណ១០លីមានប្រាសាទថ្មីមួយទៀត(២) មានបរិវេណព័ទ្ធជុំវិញប្រវែង ១០០លី។ នៅក្នុងប្រាសាទនេះ មានព្រះពុទ្ធរូបមួយអង្គទ្រង់ផ្ទុំធ្វើពីស្ពាន់ ហើយមានទឹកចេញជានិច្ចពីផ្ចិត ហូរធ្លាក់ចុះទៅក្នុងស្រះធំមួយ នៅពីខាងជើងប្រាសាទនេះ។ នៅទិសខាងជើងកំពែងនគរចំងាយប្រមាណ ៥លី មានប្រសាទមាសរាងបួនជ្រុង(៣) និងមាន បន្ទប់ថ្មជាច្រើនរយ ហើយនៅក្នុងនោះគេឃើញមានព្រះពុទ្ធរូបមាស រូបសិង្ហមាស រូបដំរី រូបគោ រូបសេះ និងវត្ថុដទៃទៀតធ្វើពីស្ពាន់ ច្រើនអិតគណនា។

១ = តាមសេចក្ដីប្រែរបស់លោក ប៉េលីយោត ថា Lou-Pan ហើយលោកចុះសេចក្ដីយល់ថាជាប្រសាទអង្គរវត្ត។ តាមចិនលូប៉ិន ជាឈ្មោះមេជាងរចនាក្នុងរឿងព្រេង ដូចខ្មែរយើងនិយាយពីពិសនុការអ្នកសាងប្រាសាទដែរ)។
២ = លោក ប៉េលីយោត យល់ថា ជាប្រាសាទមេបុណ្យខាងលិចដែលគាត់បន្ថែមថា ប្រហែលជាគេច្រលំ ជាទិសខាងកើតទៅវិញ។ ៣ =ទំនងជាប្រាសាទនាគព័ន្ធ។

## ២. ដំនាក់លំនៅស្ថាន

ព្រះដំនាក់ ផ្ទះនាម៉ឺនមន្ត្រី និងផ្ទះអ្នកមានទាំងអស់សុទ្ធតែបែរមុខទៅកើត។ ព្រះរាជដំនាក់ ស្ថិតនៅខាងជើងប្រាសាទមាស និងស្ពានមាស ហើយនៅជិតមាត់ទ្វារក៏មានបន្ទាយព័ទ្ធជុំវិញប្រវែង ៥ រឺ ៦លី។ ក្បឿងប្រក់តួប្រាសាទកន្តាលធ្វើពីសំនរ អែអគារផ្សេងទៀត សឹងប្រក់ក្បឿងធ្វើពីដីដុតពណ៌លឿង។ សសរនិងស៊ុមទ្វារសុទ្ធតែឆ្លាក់ រឺគូររូបរចនាផ្សេងៗ តែភាគច្រើនគឺរូបព្រះពុទ្ធ។ ដំបូលទាំងនោះល្អមើលណាស់។ របៀងប្រាសាទ និង ថែវយ៉ាងវែងអាចដើរបាន ជាផ្លូវខ្វាត់ខ្វែង ហើយដំបូលនោះក៏ខ្ពស់ៗសំបើមណាស់។ ទីនេះជាកន្លែងព្រះរាជវាំងដែលស្តេចទ្រង់ប្រកបកិច្ចការផែនដី មានបង្អួចមាសមួយនៅខាងស្តាំ និង ខាងឆ្វេងនៃកន្លែងស្តេចគង់ប្រថាប់ មានសសរបួនជ្រុងតំកល់កញ្ចក់តំរៀបគ្នាប្រមាណជា៤០ រឺ ៥០ បន្ទះ ដាក់ដង្ហែតាមជ្រុងបង្អួចនេះ កំនល់ទ្រមានរូបរាងជាដំរី (ត្រង់នេះគឺជាបុស្បុកមួយ ដែលមានសសរបួន និងក្បាច់លំអរដោយកញ្ចក់ជើងទ្រធ្វើពីរូបដំរី តែលោកជីតាក្វាន់ សរសេរថា ជាស៊ុមមួយ ព្រោះឃើញមានតែគ្របជុំវិញ)។

ខ្ញុំលឺគេនិយាយថា ទីត្រង់នេះ មានរបស់ប្លែកៗច្រើនណាស់ ប៉ុន្តែបំរាមតឹងតែងពេក មិនអាចអនុញ្ញាតអោយចូលមើលបាន។ ក្នុងបន្តារឿងប្លែកទាំងនោះ មានការណ៍មួយថា នៅកន្តាលប្រសាទមានប្រាង្គមាសមួយ ហើយថារាល់យប់ ស្តេចតែងឡើងទៅផ្ទុំលើប្រាង្គមាសនោះ។ អ្នកស្រុកគេមានជំនឿហើយនាំគ្នានិយាយថា នៅក្នុងប្រាសាទមាសនោះអែង មានបិសាចមួយ មានរូបពស់ក្បាលប្រាំបួន(២)។ បិសាចនោះជាព្រះភូមិរក្សាព្រះនគរ។រាល់យប់ បិសាចតែងដំនែងខ្លួនជាមនុស្សស្រី ហើយស្តេចត្រូវរួមផ្តេកផ្តិតនឹងនាងនេះ សូម្បីតែមហេសី រឺ ស្នំស្និទ្ធព្រះអង្គ ក៏មិនហ៊ានចូលទៅក្នុងទីនោះដែរ។ លុះដល់មជ្ឈឹមយាម ទើបស្តេចចេញមកពីនាងពស់នោះ មករួមរ័ក្សនឹងមហេសី រឺ ស្រីស្នំដទៃទៀតបាន។ បើបាត់ពស់នោះមិន និម្មិតមកទេ នោះថាគ្រោះថ្នាក់នឹងមកដល់អាយុស្តេចហើយ រឿងរ៉ាវអាក្រក់នឹងកើតឡើង។ បើស្តេចមិនបានយាងចូលទៅទីនោះមួយយប់ណា ហើយពេលនោះអពមង្គល នឹងពិតជាកើតឡើងភ្លាមមិនខានដែរ។

២ = ពស់ក្បាលប្រាំបួននេះគឺជានាគ ព្រោះនាគខ្មែរមានខ្លួនជាពស់ អែនាគចិនមានជើងក្បាលតូចអិតពពារទេ។

បន្ទាប់មក ដំនាក់ញាតិវង្ស រឺលំនៅនាម៉ឺន មន្ត្រីធំៗ សង់យ៉ាងធំទូលាយស្កុកស្គម្ភប្លែកពីផ្ទះអ្នកស្រុកសាមញ្ញ។ ផ្ទះទាំងនោះសុទ្ធតែប្រក់ស្លឹក មានតែផ្ទះអ្នកធំ និង វិហារទេដែលប្រក់ក្បឿង។ ហើយទំហំផ្ទះទាំងនោះត្រូវសង់ទៅតាមលំដាប់យសសក្តិនៃម្ចាស់ផ្ទះផង។ ចំនែកផ្ទះប្រជារាស្ត្រវិញ សុទ្ធតែប្រក់ស្លឹក រឺ ស្បូវ គេមិនហ៊ានប្រក់ក្បឿងទេ អែទំហំសោត សង់ទៅតាមធនធានខ្លួន តែមិនហ៊ានសង់អោយដូចលំនាំអ្នកធំឡើយ។

## ៣. សំលៀកបំពាក់ និង គ្រឿងអលង្ការ

អ្នកស្រុកទាំងអស់ ចាប់តាំងពីស្តេចចុះទៅ ទាំងស្រីទាំងប្រុស សុទ្ធតែបួងសក់ទាំងអស់ ហើយគេតែងលែងខ្លួនទទេស្អាត មានតែសំពត់មួយផ្ទាំងតូចវណ្ឋជុំវិញខ្លួន របៀបគេចង់ពុង ហើយបើត្រូវការចេញទៅណាមកណា គេយកកំនាត់មួយផ្ទាំងទៀតធំជាងមុន មករុំស្រោបថែមពីលើ។ ការស្លៀកពាក់នេះ មានលក្ខខ័ណ្ឌទៅតាមឋានៈទៀត។ ព្រះសស្ត្ររបស់ស្តេច មានតំលៃជាមាសបីបួនតំលឹងគឺល្អដាច់ពីសំលៀកបំពាក់អ្នកផងទាំងពួង។ អ្នកស្រុកនេះចេះត្បាញសំពត់ប្រើហើយ តែមានប្រើសំពត់មកពីស្រុកសៀម និង ចាមផងដែរ។ សំពត់ពិសេសមកពីបស្ចឹមប្រទេសដែលមានសាច់ម៉ដ្ឋល្អ មានតែស្តេចទេដែលមានប្រើ គឺសំពត់ផ្កាសរសៃសូត្រឆ្មារ ស្តេចពាក់មកុដមាស បើជួលកាលមិនពាក់មកុដទេ គឺពាក់កំរងផ្កាដូចជាផ្កាម្លិះជាដើម ព័ទ្ធជុំវិញព្រះសិរ។ នៅលើកំពូលព្រះកេស មានស្នៀតសក់ដាំត្បូងពេជ្រយ៉ាងធំទៀតផង។ គ្រាន់តែគ្រឿងអលង្ការដែលពាក់នៅនឹងព្រះបាទ និងព្រះហស្តមានទំងន់ដល់ទៅបីនាឡិ។ នៅគ្រប់តែម្រាមមានពាក់ចញ្ចៀនដែលមានដាំពេជ្រភ្នែកឆ្មា។ បាតព្រះហស្ត និង បាតព្រះបាទមានលាបពណ៌ក្រហម ហើយនៅពេលដែលទ្រង់យាងចេញមកម្តងៗ តែងកាន់ព្រះខាន់មាសមួយជានិច្ច។

ចំនែកប្រជារាស្ត្រវិញ មានតែស្ត្រីភេទទេ ដែលអាចលាបថ្នាំក្រហមនៅបាតដៃបាតជើងបាន អែប្រុសៗមិនហ៊ានលាបទេ។ ព្រះញាតិវង្ស និងមន្ត្រីធំអាចប្រើកំនាត់ផ្ការង្វើលៗបាន អែមន្ត្រីធម្មតាប្រើបានតែត្រឹមផ្កាចុងជាយប៉ុណ្ណោះ ចំនែករាស្ត្រសាមញ្ញ បើស្រីៗ អាចប្រើសំពត់ផ្កាបានខ្លះដែរ។

ជនជាតិចិនដែលទើបមកដល់ប្រទេសនេះថ្មីៗ ទោះបីប្រើសំពត់មានផ្កានៅជាយទាំងសងខាង ក៏គេមិនថាអីដែរ ព្រោះគេសន្មតថា ជាពួកមិនទាន់ដឹងទំនៀមស្រុក ហៅថា ពួក ង៉ានទឹង ប៉ា ឆា (មិនដឹងភាសា?)។

## ៤. អំពីមន្ត្រី

ប្រទេសនេះមានរដ្ឋមន្ត្រី មេទ័ព និងហោរា ហើយមន្ត្រីក្រោមពីនោះ មានច្រើនឋានៈទៀត ដូចជានៅប្រទេសចិនដែរ ប្លែកគ្នាតែឈ្មោះហៅ។ មន្ត្រីទាំងនេះភាគច្រើនជាពូជពង្សរបស់ស្តេច បើមានអ្នកក្រៅចូលធ្វើជាមន្ត្រីផងទាល់តែអ្នកនោះយកកូនទៅថ្វាយអោយធ្វើជាស្នំស្តេច។ ការធ្វើដំនើរនៃមន្ត្រីទាំងនោះ គេសំគាល់តាមគ្រឿងហែហាមតាមឋានៈ។ អ្នកធំជាងគេអង្គុយលើគ្រែស្នែងមាស មានបាំងក្លស់ដងមាសបួន។ អ្នកបន្ទាប់មកទៀតគ្រែស្នែងមាសក្លស់ដងមាសពីរ ចុះមកទៀតគ្រែស្នែងប្រាក់ មានក្លស់ដងមាសមួយ។ អ្នកតូចបន្តមកចេះតែថយក្លស់ដងមាសតែមួយ រួចក្លស់ប្រាក់មួយអិតមានគ្រែស្នែង។

ចំពោះមន្ត្រីដែលត្រូវជិះគ្រែស្នែងប្រាក់ និងក្លស់ដងមាសមួយឡើងទៅ សុទ្ធតែហៅ ប៉ាតេង (ម្រតេង) រឺ អាំតេង (អំដែង?)។ អ្នកដែលមានក្លស់ដងប្រាក់ ហៅថា សីលាត់ទី (ស្រីស្និន?)។ ក្លស់នោះ គេយកសំពត់ជាតិសូត្រដែលធ្វើមកពីប្រទេសចិនពាស ហើយទំលាក់ចុងរំភាយចុះសឹងដល់ដី។ អែឆ័ត្រតាំងយូរ គេយកសំពត់សូត្រពណ៌ខៀវមកពាស ហើយទំលាក់រំភាយខ្លីបបន្តិចដែរ រួចយកប្រេងមកលាបយ៉ាងរលើបទៀតផង។

៥. អំពីលទ្ធិសាសនាបីបែប

អ្នកចេះដឹង (ពួកព្រាហ្មណ៍?) គេហៅថា ប៉ាឃាប(១) លោកសង្ឃ គេហៅថា ជូគូ(២) ពួកតាបសគេហៅថា ប៉ាស៊ីវី(៣)។

១ =តាមសេចក្តីប្រែរបស់លោក ប៉េលីយោតថា ប៉ាឃី ពាក្យនេះទំនងជាមកពីពាក្យ បណ្ឌិត។ ២ លោកសង្ឃខាងពុទ្ធសាសនា ប្រហែលមកពីពាក្យព្រះគ្រូ។ ៣ = លោក ប៉េលីយោត ប្រែថា ប៉ាសិវ៉ៃ ប្រហែលមកពីពាក្យ បស្ស:

ដែលហៅថា ប៉ាឃាប នេះ មិនដឹងជារៀនពីកន្លែងណាទេ ខ្ញុំមិនដែលឃើញសាលារៀន ទីកន្លែងរៀនសោះ ខ្ញុំឃើញតែរូបពួកគេនេះអែង ដែលស្លៀកពាក់ដូចជាធម្មតាដែរ ប៉ុន្តែមានប្លែកត្រង់មានពាក់អំបោះស វេញមួយខ្សែនៅក ហើយអំបោះនេះ ពាក់ជាប់នឹងក អស់មួយជីវិត។ គេតែងរើសយកពួក ប៉ាឃាប នេះអែងធ្វើជាមន្ត្រី ព្រោះគេទុកជអ្នកចេះដឹងជាន់ខ្ពស់ហើយ។

ចំនែកលោកសង្ឃវិញ កោរព្រះកេស គ្រងចីវរពណ៌លឿងបញ្ចេញស្មាខាងស្តាំ ហើយនិមន្តដោយជើងទទេ អិតពាក់ស្បែកជើងឡើយ។ ព្រះវិហារមួយ គេអនុញ្ញាតអោយប្រក់ក្បឿងបាន ហើយនៅកន្តាលព្រះវិហារនោះមានតំកល់ព្រះពុទ្ធរូបមួយព្រះអង្គ ដែលមានភិនភាគ ដូចព្រះសក្យមុនីដែរ(៤) គេហៅថា ពុតលៃ លាបលន ពណ៌ក្រហម ដោយគេយកដីសមកសូនធ្វើហើយលាបពណ៌ផ្សេងៗ គ្មានភិនភាគអ្វីក្រៅពីនេះទេ ច្រើនតែកសាងអំពីស្ពាន់ ហើយគ្មានជួងស្គរ រគាំង ទង់អ្វីទាំងអស់។ ព្រះសង្ឃឆាន់ត្រីសាច់បាន តែមិនឆាន់ស្រាទេ ហើយគេអាចរៀបម្ហូបត្រីសាច់ទាំងនេះថ្វាយព្រះផង។ ក្នុងមួយថ្ងៃលោកនិមន្តទៅបិណ្ឌបាតពីផ្ទះអុបាសកតែមួយដងទេ ហើយគ្មានរៀបជន្តាំស្លនៅក្នុងវត្តឡើយ។ លោកឆាន់មួយដងក្នុងមួយថ្ងៃ។

៤ = តាមមហាយាន គេជឿថា មានព្រះពុទ្ធពីរអង្គ គឺព្រះពុទ្ធដើមនៅឋានសួគ៌គឺនាម អាមិតាភ: និងព្រះពុទ្ធដែលត្រាស់ដឹងនៅស្ថានមនុស្សនាម សក្យមុនី។

ធម៌ដែលសូត្រលោកសង្ឃមានច្រើនណាស់ គេក្រងនៅនឹងស្លឹកតាលព្រឹក្ស(១) ជិតស្នាមអក្សរខ្មៅ តែមិនសរសេរដោយជក់ រឺ ខ្មៅដុសឡើយ។ ខ្ញុំមិនដឹងសរសេរដោយអ្វីទេ(២)។ គេយកគ្រែស្នែង និងក្លស់ដងមាស រឺ ដងប្រាក់មកសែងមកបាំងលោកសង្ឃដែរ ព្រោះស្តេចតែងពិគ្រោះនឹងព្រះសង្ឃ ចំពោះបញ្ហាណាដែលធំៗរបស់ស្រុកទេស។ ប៉ុន្តែពុំឃើញមានដូនជីនៅក្នុងវត្តទាំងនោះទេ។

១ = បានជាខ្ញុំប្រែថា តាលព្រឹក្ស ព្រោះពាក្យដើម គេពុំទាន់បញ្ជាក់ច្បាស់ថា ស្លឹករឹតនៅឡើយទេ។ ២ = ការពិតគេចារដោយដែកចារ ហើយយកធ្យូងលាយប្រេងលុប ទើបបានជាស្នាមខ្មៅនេះ។

រីអែពួកតាបសដែលហៅ ប៉ាស៊ីវី នេះ ស្លៀកពាក់ជាអ្នកស្រុកធម្មតាដែរ តែមានជួតក្បាលកំនាត់ពណ៌ក្រហម របៀបដូចពួកស្រី តារតា នៃជនជាតិម៉ុងហ្គោលដែរ តែទាបជាងបន្តិច។ ពួកនេះមានវត្តដូចព្រះសង្ឃពុទ្ធសាសនាដែរ តែមានទំហំតូចជាង។ លទ្ធិតាបសនេះ គ្មានអិទ្ធិពលខ្លាំងដូចសាសនាព្រះពុទ្ធទេ។ ពួកនេះគេគោរពចំពោះតែថ្មមួយដុំធំ (៣) ដូចថ្មរូបអ្នកតាព្រះស្រុកដូច្នោះដែរ។ ប្រភពក្តី របៀបប្រតិបត្តិនៃពួកនេះក្តី ខ្ញុំពុំបានដឹងទេ។ ពួកនេះមានដូនជី ហើយវិហារក៏ត្រូវអនុញ្ញាតអោយប្រក់ក្បឿងបានដែរ។ ពួកប៉ាស៊ីវី មិនបរិភោគរបស់អ្នកដទៃទេ ហើយមិនបរិភោគនៅចំពោះមុខទីសាធារណៈផង ហើយមិនសេពសុរាជាដាច់ខាត។ ខ្ញុំមិនដែលឃើញតាបសសូត្រធម៌ រឺក៏ធ្វើអំពើអ្វីជាប្រយោជន៍អ្នកផងច្បាស់នឹងភ្នែកម្តងណាឡើយ។

៣ = លោក ប៉េលីយោតយល់ថា ជាលិង្គ។

ចំនែកក្មេងៗកូនអ្នកស្រុកវិញ ដែលត្រូវការរៀនសូត្រ គេតែងយកទៅទុកដាក់រៀនជាមួយព្រះសង្ឃហើយបួសជា

ព្រះសង្ឃផង លុះដល់អាយុច្រើនក៏វិលត្រលប់មកកាន់ជីវភាពជាជនធម្មតាវិញ។ អែការល្អិតល្អន់ជាងនេះទៅទៀត ខ្ញុំមិនបានដឹងអោយច្បាស់លាស់ឡើយ។

Website : www.khmercenter.ch មណ្ឌលវប្បធម៌ខ្មែរនៅប្រទេសស្វីស
ជាសេវាកម្ម ក្នុងការផ្សាយពុទ្ធសាសនា វប្បធម៌ ជាភាសាខ្មែរ

Khmer Culture Center in Switzerland,
Phone (41)44 3635900 , Fax (41)44 3635900
© 2004 The Switzerland Buddhist Society, (watkhmer) Inc. All rightsreserved.